# កម្មវិធីឃ្លាំមើលសវនាការសាលាក្តីខ្មែរក្រហម




Asian International Justice Initiative (AIJI), a project of East-West Center and the WSD HANDA Center for Human Rights and International Justice at Stanford University (previously known as the UC Berkeley War Crimes Studies Center)

# របាយការណ៍សង្ខេបប្រចាំសប្តាហ៍ លេខ ៧៦

នាសប្តាហ៍នេះ អង្គជំនុំជម្រះសាលាដំបូងបានស្តាប់សក្ខីកម្មសាក្សីចំនួនបួននាក់ ក្នុងអំឡុងពេលបួនថ្ងៃ ដោយបានផ្អាកកិច្ចដំណើរការនីតិវិធីសវនាការនៅថ្ងៃព្រហស្បតិ៍ ដើម្បីរៀបចំកិច្ចប្រជុំជាអសាធារណៈ ស្តីពីការគ្រប់គ្រងសវនាការ។[1] សាក្សីដំបូងគេក្នុងសប្តាហ៍នេះដែលជាសាច់ញាតិឆ្ងាយរបស់លោក **សៅ ភឹម** គឺលោក **សីន អ៊ឹង** បានបិទបញ្ចប់ការផ្តល់សក្ខីកម្មរបស់គាត់ដែលបានបន្តកាលពីសប្តាហ៍មុននោះ ដោយបានប្រាប់តុលាការឲ្យដឹងពីបទពិសោធន៍របស់គាត់ផ្ទាល់ ដែលបានរួមដំណើរអមអតីតថ្នាក់ដឹកនាំភូមិភាគបូព៌ា ទៅកាន់ទីក្រុងភ្នំពេញ នៅមុនពេលដែលលោក **សៅ ភឹម** បានធ្វើអត្តឃាតខ្លួនឯង។ សាក្សីបន្ទាប់ដែលបានមកផ្តល់សក្ខីកម្មគឺលោក **នួន ត្រេច** ជាអតីតសមាជិកនៃកងពលលេខ ៣១០ ដែលកងពលរបស់គាត់ត្រូវបានចោទប្រកាន់ថាត្រូវបោសសម្អាតក្នុងរបបនោះផងដែរ។ នៅថ្ងៃអង្គារ សាក្សីដែលមានអាយុ៩៣ឆ្នាំ មានអត្តលេខ **2-TCW-920** បានផ្តល់សក្ខីកម្មតាមរយៈប្រព័ន្ធសោតទស្សន៍ពីខេត្តបាត់ដំបង។ សាក្សីរូបនេះដែលត្រូវបានកំណត់ដោយប្រើ

[1] កិច្ចប្រជុំស្តីពីការគ្រប់គ្រងសវនាការ ត្រូវបានរៀបចំដើម្បីពិភាក្សាអំពី៖ “១)ចំនួនទំព័រនៃសារណាសន្និដ្ឋានបញ្ចប់ការពិភាក្សាដេញដោល ២)ការកំណត់កាលបរិច្ឆេទសម្រាប់ការធ្វើពាក្យប្តឹងទៅលើសារណាសន្និដ្ឋានបញ្ចប់ការពិភាក្សាដេញដោល ៣) ការរៀបចំកាលវិភាគសម្រាប់ការថ្លែងសារណាសន្និដ្ឋានបញ្ចប់ការពិភាក្សាដេញដោល ៤) ការកំណត់ទម្រង់ និងពេលវេលានៃការដាក់បញ្ចូលលិខិតបទដ្ឋានគតិយុត្តដែលកំពុងអនុវត្ត និង ៥) ផលប៉ះពាល់ ប្រសិនជាកើតមាន ពាក់ព័ន្ធនឹងសាលដីការបស់អង្គជំនុំជម្រះតុលាការកំពូល ស្តីពីការបិទបញ្ចប់កិច្ចដំណើរការនីតិវិធីសវនាការស្តាប់ភស្តុតាងលើសំណុំរឿង០០២ វគ្គ២” ដោយអនុលោមតាម សេចក្តីសម្រេចដែលធ្វើឡើងដោយអង្គជំនុំជម្រះសាលាដំបូង ស្តីពី “សារណាសន្និដ្ឋាបិទបញ្ចប់កិច្ចពិភាក្សាដេញដោល សាលដីការបស់អង្គជំនុំជម្រះតុលាការកំពូលក្នុងសំណុំរឿង០០២ វគ្គ១ និងកិច្ចប្រជុំស្តីពីការគ្រប់គ្រងសវនាការ” ចុះថ្ងៃទី៣ ខែវិច្ឆិកា ឆ្នាំ២០១៦) ឯកសារ E449។

ប្រាស់ត្រឹមតែរហស្សនាមនោះ គឺជាអ្នកនាំសាររវាងលោក **នួន ជា** និងលោក **រស់ ញឹម** ក្នុងទសវត្សរ៍ឆ្នាំ១៩៦០។ សាក្សីចុងក្រោយក្នុងសប្តាហ៍នេះ មានអត្តលេខ **2-TCW-971** ក៏បានផ្តល់សក្ខីកម្មតាមរយៈប្រព័ន្ធសោតទស្សន៍ផងដែរពីខេត្តឧត្តរមានជ័យ ស្តីពីការបញ្ជូនខ្លួនរបស់គាត់ពីខេត្តតាកែវទៅកាន់ខេត្តបាត់ដំបង ដើម្បីដោះស្រាយនូវបញ្ហាកង្វះខាតស្បៀងអាហារនៅទិសពាយព្យ តែទោះបីជាយ៉ាងនេះក្តី សក្ខីកម្មរបស់គាត់ត្រូវបានកាត់ផ្តាច់ដោយសារតែបញ្ហាប្រព័ន្ធភ្ជាប់ប្រព័ន្ធអ៊ីនធើណេតមិនល្អ។

---

* របាយការណ៍នេះ ត្រូវបានសរសេរដោយ ម៉ាយខល ចេន (Michael Chen), ហាន់ណា ដេយឆ៍ (Hanna Daych), ខេតលីន កាហ្វ្រៀ (Caitlin McCaffrie), និន វុទ្ធី, លូវីស រេតវ៉ាយលើ (Louise Rettweiler), តាយ លីណា, ធំ ស្ថាពរ និង ភីនីឡូភី វ៉ាន់ធូល (Penelope Van Tuyl) ដែលជាផ្នែកមួយនៃកម្មវិធីឃ្លាំមើលសវនាការសាលាក្តីខ្មែរក្រហម និងការផ្សព្វផ្សាយតាមសហគមន៍របស់អង្គការគម្រោង ផ្តួចផ្តើមយុត្តិធម៌អន្តរជាតិប្រចាំអាស៊ី (AIJI)។ AIJI គឺជាគម្រោងកិច្ចសហប្រតិបត្តិការរវាងមជ្ឈមណ្ឌលបស្ចិម-បូព៌ា (East-West Center) នៅអូណូឡូឡូ (Honolulu) និងមជ្ឈមណ្ឌល ដាប់ប៊ែលយូ.អេស.ឌី ហាន់ដាសម្រាប់សិទ្ធិមនុស្ស និងយុត្តិធម៌អន្តរជាតិ (The WSD HANDA Center) ដែលកាលពីមុនត្រូវបានគេស្គាល់ថាជា មជ្ឈមណ្ឌលសិក្សាអំពីឧក្រិដ្ឋកម្មសង្គ្រាម ប៊ែកឃ្លី (Berkeley War Crime Study Center)។ ចាប់តាំងពីឆ្នាំ២០០៣មក មជ្ឈមណ្ឌលទាំងពីរនេះ បានកំពុងធ្វើកិច្ចសហប្រតិបត្តិការគ្នាលើគម្រោងជាច្រើន ដែលពាក់ព័ន្ធនឹងការបង្កើតការផ្តួចផ្តើមយុត្តិធម៌ និងកម្មវិធីកសាងសមត្ថភាពនានាក្នុងវិស័យសិទ្ធិមនុស្សប្រចាំតំបន់អាស៊ីអាគ្នេយ៍នេះ។

EAST-WEST CENTER

AIJI TRIAL MONITORING

WSDHANDACENTER
FOR HUMAN RIGHTS & INTERNATIONAL JUSTICE
Stanford University